2023.12
សមាគមGTS

# ជូនទៅកាន់កម្មសិក្សាការីទាំងអស់គ្នា

ចូលដល់ខែធ្នូ អាកាសធាតុកាន់តែត្រជាក់។
កម្មសិក្សាការីទាំងអស់គ្នា តើអ្នកសុខសប្បាយជាទេ?

ឃើញថាមួយរយៈនេះការពាក់ម៉ាស់របស់មនុស្សម្នាទូទៅមានការបន្ធូរបន្ថយ ស្របពេលជាមួយនឹងការឆ្លងនៃមេរោគកូវ៉ូណាក៏បានថយចុះដែរ ប៉ុន្តែទោះជាយ៉ាងនេះក្ដីសូមបន្តចាត់វិធានការគ្រប់គ្រងការឆ្លងមេរោគឱ្យបានហ្មត់ចត់ និង វិធានការបង្ការ។

លើសពីនេះទៅទៀតក្នុងអំឡុងពេលថ្ងៃឈប់សម្រាកយូរ មានការប្រើប្រាស់អគ្គិសនីយខ្ជះខ្ជាយ។ សូមព្យាយាមសន្សំសំចៃអគ្គិសនី ហើយប្រយ័ត្នពេលចេញទៅក្រៅដោយបើកម៉ាសីុនកំដៅចោល។

សូមចងចាំ ខាងក្រោមនេះជាចំនុចប្រុងប្រយ័ត្នសម្រាបការឈប់សម្រាកថ្ងៃបុណ្យឆ្លងឆ្នាំ និង ចូលឆ្នាំសកល។

## ចំណាំ

### 1.អំពីជំងឺ

វីរុសកូវ៉ូណាថ្មីការការពារជំងឺផ្ដាសាយ ផ្ដាសាយធំប្រភេទថ្មី

- ពេលត្រលប់មកពីខាងក្រៅ, មុនចំអិនអាហារដាច់ខាតត្រូវលាងដៃនិងខ្ពុរមាត់។
- ត្រូវរស់នៅដោយត្រឹមត្រូវទៅតាមច្បាប់ ◌◌ះ(កុំនៅដល់យប់ជ្រៅពេក)
- ត្រូវយកចិត្តទុកដាក់ទៅលើរបបអាហារញ៉ាំដែលផ្ដល់ជីវជាតិគ្រប់គ្រាន់។

https://www.otit.go.jp/CoV2_jissyu_kansen/ ←សូមពិនិត្យនៅទីនេះ សំរាប់ការបញ្ជាក់បន្ថែម

### 2. អំពីគ្រោះថ្នាក់ចរាចរណ៍

ត្រូវគោរពច្បាប់ចរាចរណ៍ប្រទេសជប៉ុនអោយបានខ្ជាប់ខ្ជួន ដើម្បីកុំអោយជួបគ្រោះថ្នាក់ចរាចរ

សិនបើមានគ្រោះថ្នាក់កើតឡើង
ទូរស័ព្ទដៃជាមួយនិងកាតស្នាក់នៅ និងកាតទំនាក់ទំនង, នៅពេលកើតស្ថានភាពមិនបានគ្រោងទុក ត្រូវរក្សាអារម្មណ៍ ហើយសូមទំនាក់ទំនងទៅអ្នកស្នាក់នៅជាមួយ និងសមាគម
លើសពីនេះ, ត្រូវគោរពច្បាប់ចរាចរពេលជិះកង់។ គោរពច្បាប់ចរាចរ គឺគោរពជីវិតខ្លួនឯង

### 3. អំពីការងារក្រៅម៉ោង

ការងារក្រៅម៉ោងនិងការងារធ្វើតាមផ្ទះ ត្រូវបានហាមឃាត់មិនឲ្យកម្មសិក្សាការីធ្វើនោះទេ!
ថ្វីបើទទួលបានសិទ្ធស្នាក់នៅក៏ដោយ មានន័យថាអ្នកជាកម្មសិក្សាការីកហាត់ជំនាញគឺ "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 1R" និង "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 2 R"។
ការទទួលយកប្រាក់ឈ្នួលនៅតាមគ្រឹះស្ថាននិងហាងផ្សេងៗគឺជាសកម្មភាពខុសច្បាប់ ហើយនឹងបណ្តាលឲ្យក្រុមហ៊ុននិងសមាគមរបស់អ្នកត្រូវទទួលទោសផងដែរ!
លើសពីនេះទៅទៀតវាជាសកម្មភាពមួយខុសពីការហ្វឹកហ្វឺនជំនាញជាក់ស្តែង ហើយអ្នកនឹងត្រូវបញ្ជូនវិលត្រឡប់ទៅផ្ទះវិញ។

### 4. អំពីការរញ្ជួយដី

ប្រទេសជប៉ុនត្រូវបានគេដឹងថាជាប្រទេសដែលមានការរញ្ជួយដីជាច្រើន។
ប្រសិនបើមានការរញ្ជួយដីកើតមានឡើងតើអ្នកគួរធ្វើអ្វី? តើអ្នកទាំងអស់គ្នាដឹងដែរឬទេ?
បន្ទាប់ពីអ្នកមើលសៀវភៅ（ http://www.fdma.go.jp/relocation/bousai_manual/index.html ） ស្តីពីសៀវភៅណែនាំអំពីការការពារគ្រោះមហន្តរាយរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយនិងទីភ្នាក់ងារអគ្គីភ័យ អ្នកនឹងទទួលបានទទួលចំណេះដឹង។

### 5.ផ្សេងៗ

ដាច់ខាតត្រូវគោរពច្បាប់ក្រុមហ៊ុន ច្បាប់នៅកន្លែងស្នាក់នៅ និងច្បាប់របស់ប្រទេសជប៉ុន។
ឧក្រិដ្ឋជនត្រូវបានដាក់ទោសដោយមិនគិតពីជនជាតិជប៉ុនឬជនបរទេសឡើយ។
ប្រសិនបើអ្នកធ្លាប់ជាប់បទព្រហ្មទណ្ឌហើយ អ្នកនឹងមិនអាចលុបប្រវត្តិនោះបានទេ។

- ហាមឃាត់ការស្នាក់ខាងក្រៅដោយមិនមានការអនុញ្ញាត។ ចូរសុំច្បាប់ពីក្រុមហ៊ុនឬសមាគមជាមុនសិន។
- គ្រូបង្រៀនណែនាំការរស់នៅអាចនឹងដើរត្រួតពិនិត្យកន្លែងស្នាក់នៅគ្រប់ពេល ! ប្រសិនបើមានបញ្ហា អ្នកត្រូវតែទាក់ទងទៅសមាគមផង។វានឹងមានការលំបាកស្នើសុំបច្ចុប្បន្នភាព VISA ទៅកាន់អន្តោប្រវេសន៍ ប្រសិនបើអ្នកត្រូវបានគេបញ្ជាក់ថាអាកប្បកិរិយាក្នុងការរស់នៅរបស់អ្នកមិនល្អ។
  នេះជាច្បាប់ដើម្បីឲ្យអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុវត្ថិភាពតែប៉ុណ្ណោះ !
  ដូចនេះហើយអ្នកត្រូវគោរពវិន័យ ហើយកុំសប្បាយមួយពេលដែលធ្វើឲ្យអ្នកខូចអនាគត !

## ការលួចទំនិញតាមហាង និងជិះកង់ដែលគេទុកចោលទាំងនេះគឺជាអំពើខុសច្បាប់ ដែលមិនអាចលើកលែងបាន !

ជាអកុសលមានការកើនឡើងចំនួនករណីឧក្រិដ្ឋកម្មដែលបង្ករដោយក្នុងពេលរីកហាត់ជំនាញ !
មិនត្រូវជឿពាក់លួងលោមសូម្បីតែជាជនជាតិដូចគ្នា។ពាក្យផ្អែមល្ហែមគឺជាអន្ទាក់។សូមជឿជាក់លើខ្លួនឯង !

មិនត្រូវឲ្យលិខិតឆ្លងដែននិងប័ណ្ណស្នាក់ទៅកាន់នរណាម្នាក់ក្រៅពីសមាគម ឬក្រុមហ៊ុនទេ !

អ្នកនឹងមិនតម្រូវឲ្យស្នើរដោយផ្ទាល់ខ្លួននៅខាងអន្តោប្រវេសន៍ទេ។ជនខិលខូចតែងតែចង់បានលិខិតឆ្លងដែន ឬប័ណ្ណស្នាក់នៅរបស់អ្នក!

សូមប្រុងប្រយ័ត្ន!

ចប់